Free
សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
978-677-7163 • VISIT KHMERPOST.US




## ព័ត៌មានសំខាន់ៗខាងក្នុង...

### ពិធីបុណ្យកាន់បិណ្ឌនៅឡូវែល

*សូមអាននៅទំព័រទី ០២*



### កម្មវិធីថែទាំមនុស្សចាស់នៅលីន

*សូមអាននៅទំព័រទី ០៧*



### A Panel Discussion on History and Legacy of Cambodia's 1991 Paris Peace Accords Will Be Held at ....

*Please Read Page 10*




### រឿងប្រលោមលោក "រឿងកុមារយោធិន"

*សូមអាននៅទំព័រទី ១១*



# ក្រុមសិល្បៈសមាគមអង្គរចេញសំដែងរឿង"ភ្លៀងនិងជីវិត"

ដោយខ្មែរផុសស.រ.អា.

យើងបានទៅទស្សនារបាំខ្មែរ កាលពីថ្ងៃទី៦តុលា ជាមួយប្រជាពលរដ្ឋឡូវែលប្រមាណជាង២០០នាក់ ដែលបាននាំគ្នាទៅទស្សនាទស្សនីយភាពនៃវប្បធម៌ខ្មែរ នៅសាលមហោស្រព

តទៅទំព័រទី០៨



## បាតុកម្មប្រឆាំងនឹងវត្តមាន ហ៊ុន សែន នៅញ៉ូយ៉ក

ដោយក្រុមនារី នាងលាភ-អេនី-ផល្លីន

រៀបរាប់ពីការនឿយហត់ពេញ១ថ្ងៃ បន្ទាប់ពីបានទៅធ្វើបាតុកម្មជាមួយប្រជាពលរដ្ឋខ្មែរនៅឡូវែលនាទីក្រុងញូយ៉ក ប្រឆាំងនឹងជនផ្តាច់ការ ហ៊ុន សែន ដែលមានវត្តមាននាបូរីអ.ស.ប. កាលពីម្សិលមិញគឺថ្ងៃទី២៩កញ្ញា២០១៨ នាងលាភ-អេនី-ផល្លីន និយាយថា ពួកខ្លួន "មានសេចក្តីរីករាយណាស់ដែលបាន

តទៅទំព័រទី០២




## ខួប១០០ឆ្នាំនៃចំការ"វើរីល"នៅខុងខត

ដោយខ្មែរផុសស.រ.អា

ចំការដែលមានទំហំ ៣០០អេគី របស់គ្រួសារវើរីលនៅខុងខតមានអាយុ ១០០ឆ្នាំ ហើយម្ចាស់ចំការ លោក វើរិល នឹងភរិយា ប្រារព្ធខួបទី១០០នេះ កាលពីថ្ងៃអាទិត្យទី៥តុលា២០១៨ នៅលើទីធ្លាដ៏ធំទូលាយនាចំការវើរីលរបស់គ្រួសារគាត់។ ភ្ញៀវមិនតិចជាង១០០០នាក់ទេ ដែលមកចូលរួមកំសាន្តពិធីខួប១០០ឆ្នាំនោះ គេមានរៀបចំ

តទៅទំព័រទី០៣




មេធាវី លុយហាស្គែល
Law Office of Louis S. Haskell
Serving the Cambodian Community since 1987
PERSONAL INJURY របួសរាងកាយ
AUTO ACCIDENTS គ្រោះថ្នាក់ចរាចរ


978-459-8359
16 Pine Street - Lowell, MA | www.attorneyhaskell.com


ឱសថស្ថាន សេនធូរី
CENTURY PHARMACY
ផ្តល់នូវសេវាកម្មពិសេស និងផ្តោតលើតំរូវការរបស់អតិថិជនម្នាក់ៗ
ថ្នាំផ្សំមានប្រសិទ្ធភាពស្របតាមវេជ្ជបញ្ជា
វិចខ្ចប់ដោយផ្លាស្ទិក
ដឹកជញ្ជូនដោយឥតគិតថ្លៃក្នុងឡូវែល, ឆែមហ្វឺត, ទឹងប្ឆូរ, តេសប៊ឺរី, ដ្រាខេត, ឡូវិន
ងាយស្រួលក្នុងការផ្ទេរវេជ្ជបញ្ជាពីឱសថស្ថានមួយទៅឱសថស្ថានផ្សេងទៀត
មានជំនួយការខាងឱសថជនជាតិខ្មែរ
www.centuryrx.net
937 Gorham Street • Lowell, MA 01852
978-455-6554 • Fax: 978-455-9476

តមកពីទំព័រទី ០១

# បាតុកម្មប្រឆាំងនឹងវត្តមាន ហ៊ុន សែន



បាតុករសង្គ្រោះជាតិ

បំពេញភារកិច្ចបង្ហាញពិភពលោកពីមុខមាត់អាក្រក់របស់ជនផ្តេចការ ដែលហ៊ានមកបំភ័ន្តមតិមហាជននៅអ.ស.ប.ថាខ្លួនបានធ្វើអ្វីខ្លះ ដែលជាប្រយោជន៍ដល់ប្រទេសខ្មែរ ក្រៅតែពីបំផ្លិចបំផ្លាញប្រទេសជាតិឯងនោះ...!" នាងលាភបន្តថា ខ្ញុំបានដើរជាក្រុមយ៉ាងឆ្ងាយតាមដងវិថីបើកផ្លូវដោយប៉ូលីសញូយ៉ក រហូតដល់ផ្ទះសំណាក់ "ហ៊ៀលតុន" ដែលក្រុមកំដរ ហ៊ុន សែន មកសំណាក់នៅទីនោះ ខ្ញុំបានស្រែកជេរពេញទំហ៊ឹងបើកកកាយពីអំពើក្បត់របស់ពួកវាចំពោះប្រជាជនខ្មែរ ហើយមានទាំងលើកកែននឹងនាំគ្នាមកអបអរនឹងជនបំផ្លាញជាតិទៀត...!" នាងអេទីបន្ទរថា "ប្រយ័ត្នមានផ្តែមកយកការចូលមកលាយឡំជាមួយពួកយើង...!"


នាង លាភ , នាង អេដនី និងនាង ផល្លីន



បាតុករគាំទ្រលោក ហ៊ុន សែន

នៅពេលឃើញជនចំឡែកចេញពីជួរក្រុមប្រជាជនមកខាងក្នុងបរិវេណក្រុមសង្គ្រោះជាតិ...ចំណែកនាង ផល្លីន បន្ថែមថា "ប៉ូលីសគេឱ្យ យើងជាបាតុករនៅជាក្រុមម្ខាងទុកឱ្យក្រុមគាំទ្រ ហ៊ុន សែន នៅជាក្រុមម្ខាងទៀត មានចំនួនប្រហាក់ប្រហែលគ្នា ហើយនៅចន្លោះទាំង២ក្រុមនោះ មានបាតុករបរទេសផ្សេងទៀត ដូចជាពួកស៊ីរីពួកចិន... ដែលធ្វើបាតុកម្មដូចគ្នាប្រឆាំងនឹងរដ្ឋាភិបាលរបស់គេ... តែខាងក្រុមគាំទ្រគណបក្សប្រជាជនឯណោះមានមួយចំនួនជិះយន្តហោះមកពីស្រុកខ្មែរទាំងក្រុមមកតែម្តង(ព័ត៌មាននិយាយថា ហ៊ុន សែន ជួលយន្តហោះប៊ូអ៊ីងបរទេសមួយគ្រឿងមកកាន់ញូយ៉កក្នុងតម្លៃ៧០ម៉ឺនដុល្លា នាំយកមកទាំងអ្នកឧកញ៉ានិងក្រុមអ្នកកាសែតផ្ទាល់ខ្លួនមកជាមួយផង) ហើយនឹងក៏មានអ្នកខ្លះទៀតជិះប៊ីសមកពីរដ្ឋផ្សេងៗដែរ មានចំនួន៣រថយន្តក្រុងមកសំណាក់នៅសណ្ឋាគារហ៊ីលតុននោះជាមួយគ្នា"។

តាមពិតទៅបាតុកម្មរបស់ក្រុមសង្គ្រោះជាតិនៅញូយ៉កនេះ មានដល់ទៅ២ក្រុម ក្រុមមួយទៀតនោះ ធ្វើនៅថ្ងៃ២៨កញ្ញា គឺ១ថ្ងៃមុន ដែលសកម្មភាពនេះក៏ក្លាយជាទម្លាប់ធ្វើតាមក្រុមថ្ងៃទី២៩ស្ទើរគ្រប់ពេលវេលា ដើម្បីកុំឱ្យជាន់ជាមួយគ្នាតែប៉ុណ្ណោះ ហើយស្រែកថា "តែសង្គ្រោះជាតិបែកបាក់គ្នា យើងស្លាប់ជាមិនខាន..." ក្រុមសង្គ្រោះជាតិ "អេ" នេះមាននិន្នាការជាសង្គ្រោះជាតិ តែដឹកនាំដោយលោកអតីតប្រធាន សម រង្ស៊ី លោកស្រីតំណាងរាស្ត្រ ជូឡុង សូមូរ៉ា លោកតំណាងរាស្ត្រ អនុប្រធាន អេង ឆៃអ៊ាង, ការនៅមិនជុំគ្នាដ៏ចម្លែកនេះ បានត្រូវអ្នកគាំទ្រពន្យល់ថា លោក សម រង្ស៊ី ត្រូវការដំណែងមួយដើម្បីធ្វើការផ្លូវទូត ដែលមានតែលោក សម រង្ស៊ី តែម្នាក់ប៉ុណ្ណោះ ដែលអាចធ្វើបានប្រសើរបំផុត សម្រាប់ប្រជាជាតិ។ ប៉ុន្តែអវត្តមានលោក សម រង្ស៊ី នៅញូយ៉កលើកនេះ បានត្រូវគេទិទានថា និយាយកុហកក្រុមរបស់ខ្លួនទៅវិញ ពីព្រោះគេបានសង្ឃឹមហើយនិយាយតៗគ្នាថា "លោកប្រធាននឹងមកគាំទ្រសកម្មភាពសកម្មជនរបស់ខ្លួន នៅញូយ៉កលើកនេះ" មិនតែប៉ុណ្ណោះទេ អវត្តមាននេះក៏បានត្រូវ ហ៊ុន សែន យកទៅប្រើសម្រាប់បកស្រាយទន្ទឹមគ្នាមានន័យថា "កំសាក" ផ្ទុយពីបំណងសង្គ្រោះជាតិយ៉ាងដំណាំសម្រាប់ជាព័ត៌មានឃោសនាបំបាក់ទឹកចិត្តពលរដ្ឋក្នុងស្រុកយ៉ាងគួរឱ្យជឿបាន។

បាតុករសង្គ្រោះជាតិប្រមាណជា១ពាន់នាក់ នាថ្ងៃទី២៩ បានសម្តែងការខឹងសម្បារចំពោះសុន្ទរកថា លោក ហ៊ុន សែន ទៅកាន់អង្គការសហប្រជាជាតិ ដែលនៅពេលលោកឡើងនិយាយនោះ អ្នកស្តាប់ក្នុងវេទិការផ្លូវការមិនបាននៅទះដៃឱ្យលោកច្រើនទេ តទៅទំព័រទី ០៨



តមកពីទំព័រទី ០១

# ខួប១០០ឆ្នាំនៃចំការ"វើរិល"នៅខុងខត

ជាការប្រគួតជាល្បែងកំសាន្តនានា ដែលក្មេងចាស់អាចឈ្នះរង្វាន់ ហើយប្រាក់ចំណូលក៏ក្លាយជាថវិការជួយដល់មន្ទីពេទ្យនឹងការព្យាបាលប្រជាជន ដែលគ្រួសារ "វើរិល"តែងតែយកចិត្តទុកដាក់ច្រើនឆ្នាំមកហើយ។

មកចាប់ដីនៅទីតាំង"ខុងចតនេះតាំងពីឆ្នាំ១៨១៨ គ្រួសារ"វើរិល"ជំនាន់ទី១ ប្រកបអាជីវកម្មចិញ្ចឹមសត្វលក់ទឹកដោះគោឱ្យអតិថិជនតាមផ្ទះក្នុងតំបន់មានគោសេះជាដើម ឥឡូវបានប្តូរមកជាកសិដ្ឋានទៅវិញ តាំងពីឆ្នាំ១៩៩០មក ហើយប្រើបុគ្គលិក ១០០នាក់ គាត់សង្ឃឹមថាថ្ងៃក្រោយមានខ្មែរ ដែលចូលចិត្តវិស័យកសិកម្មចូលមកជួយជាបុគ្គលិកកសិដ្ឋាន"វើរិល"នេះដែរ។



គ្រួសារ វើរិល ជំនាន់ទី២











យើងនាំគ្នាជិះរទេះ"ហេយរ៉ាយ"ទៅមើលអាគារដ៏ធំធេងនោះ ដែលបានធ្វើឱ្យកូនប្រុស "អេដេន"នឹងក្មួងឯទៀតៗសប្បាយខ្លាំងណាស់, យើងអាចឃើញដំណាំដាំដុះច្រើន"អេកឺ"ដែលលូតលាស់ ដោយខ្លួនឯង ពីព្រោះមានប្រព័ន្ធទឹកកប់ក្នុងដីនឹងដីដ៏មានជីវជាតិ ដាក់ដំណាំដែលគេបណ្តុះក្នុងរោង កាលពីរដូវរងាក៏ផ្តើមដុះយ៉ាងលឿននៅខាងក្រៅនារដូវក្តៅមកដល់ ។ លោក"វើរិល"ប្រាប់យើងថា"នៅមានរោងខ្លះទៀតដែរ ដែលយើងមានបញ្ចេញលក់ផលិតផងដំណាំនៅខែរងាខ្លះទៀត តែមិនច្រើនទេ ។

ថ្វីត្បិតតែពេលធ្វើការនារដូវក្តៅ គេនាំគ្នាធ្វើការ៧ថ្ងៃក្នុងមួយអាទិត្យទាំងផលិតដំណាំនឹងលក់ផលិតផលទាំងនោះផង តែនៅខែមករា ឬកុម្ភៈ ក៏មានពេលសម្រាកជិះនាវា"គ្រូស៍"ទៅកំសាន្តនៅកោះ"បាហាម៉ាស" ឬទីផ្សេងៗជារៀងរាល់ឆ្នាំដែរ មុននឹងត្រឡប់មកបន្តការងារដែលនៅរង់ចាំសម្រាប់ឆ្នាំថ្មីទៀតដែរ។

ថ្ងៃនេះពីធីខួប១០០ឆ្នាំ បានចាប់ផ្តើមនៅម៉ោង១១ព្រឹក ធាតុអាកាសក៏ក្តៅស្រួល ពន្លឺថ្ងៃក៏ចេញមកជួយកំដៅព្រះធរណីធ្វើឱ្យពិធីបុណ្យនាថ្ងៃនេះ ប្រកបដោយភាពរីករាយឥតឧបមា គេនាំគ្នាប្រគួតគ្រប់កម្មវិធី ដែលខ្លះត្រូវឈរចាំបន្តកន្ទុយយ៉ាងអន្ទះសារ ខ្លះទៀតក៏នាំកូនជិះកូនលា "ផនីយ" ខ្លះក៏ទៅជិះសេះកំសាន្តខ្លួនឯង...បើហត់ហើយ មកភ្លក់"ការ៉េមគី អាយស្ត្រីម"ស្រស់ៗរបស់អ្នកចំការ"វើរិល" រួចយើងទៅជិះ"ហេរ៉ាយ" នៅដំណើរចុងក្រោយនៅម៉ោង៣រសៀល ជាទីបញ្ចប់កិច្ចដ៏គួរឱ្យចងចាំសម្រាប់ចុងរដូវក្តៅឆ្នាំនេះណាស់។






# ពិធីបុណ្យកាន់បិណ្ឌនៅឡូវែល

ដោយខ្មែរផុសស.រ.អា.

យើងបានទៅចូលរួមពិធីកាន់បិណ្ឌមួយ នាថ្ងៃទី៣កញ្ញានេះ ដែលជាថ្ងៃកាន់និណ្ឌទី១០ នៅវត្ត"សាមគ្គីសន្តិការាម"ដែលឋិតនៅលើផ្លូវ"ធីងបូរ៉ូ" នៃក្រុង"ឆែមហ្វឺត"ខាងជើងជាប់គ្នានឹងឡូវែល ដ៏សម្បូរប្រជាពលរដ្ឋខ្មែររស់នៅ -ថ្ងៃនោះជាវេនលោកតាអាចារ្យ ធូ សារឿន នឹងក្រុមលោកយាយទេព ច័ន្ទឈឿន ។ ការកាន់បិណ្ឌគឺជាផ្នែកមួយនៃពិធីបុណ្យប្រចាំឆ្នាំដ៏ធំមួយ តាមគន្លងប្រពៃណីនៃព្រះពុទ្ធសាសនា គឺបុណ្យ"ភ្ជុំបិណ្ឌ"ដែលគេប្រារព្ធចំនួន១៥ថ្ងៃ គឺនៅ១៤ថ្ងៃដំបូង ពីថ្ងៃទី២៩កញ្ញាដល់ទី៩ តុលា២០១៨ គេកាន់វេនម្នាក់ម្តងៗ ហើយនៅថ្ងៃទី១៥គឺជាថ្ងៃប្រារព្ធនៃពិធីបុណ្យ"ភ្ជុំបិណ្ឌធំ" ជាទីបញ្ចប់ ។


វេរចង្ហាន់ប្រគេនព្រះសង្ឃ


លោកអាចារ្យ ធូ សារឿន ជូនពរដល់ពុទ្ធបរិស័ទ

ពុទ្ធបរិស័ទ ដែលភាគច្រើនជាស្ត្រីចំណាស់ ឬក៏យាយៗប្រមាណ៥០-៦០នាក់ បានមកចូលបុណ្យជាបច្ច័យ សម្រាប់ទ្រទ្រង់វត្តនឹងព្រះសង្ឃដែលគង់នៅទីនោះ ធ្វើឱ្យលោកតាអាចារ្យធ្វើការជូនពរយ៉ាងញឹកញាប់, ខ្លះទៀតក៏នាំមកនូវចង្ហាន់មកទាំងស្រាក់ ឬក៏ទាំងស្លក មានក្លិនឈ្ងុយឆ្ងាញ់មកប្រគេនព្រះសង្ឃ គឺជាម្ហូបដ៏ប្រណិតដែលម្ចាស់ខ្លួនឯង ស្ទើរមិនហ៊ានទីញមកបរិភោគផង ពីព្រោះគេមានជំនឿថា"នាអម្លុង១៥ថ្ងៃនេះ ជីដូនជីតា ម្តាយឪពុក មាមីង ...ដែលបានចាកឋានពិលោកនេះទៅ អាចនឹងមានរងទុក្ខសោក ហើយអាចនឹងត្រឡប់មករកបងប្អូន ដើម្បីទទួលម្ហូបអាហារដែលជាទាននេះ មកបរិភោគ នាឱកាសបុណ្យភ្ជុំបិណ្ឌ" ហេតុនេះហើយ ត្រូវធ្វើឱ្យបានល្អឱ្យបានច្រើន បានជាមានម្ហូបអាហារយ៉ាងសម្បូរហូរហៀរហូតដល់ខ្វះខ្វាយ នាឱកាសនោះ។ ព្រះសង្ឃ៦អង្គនៃវត្ត"សាមគ្គីសន្តិការាម" តែងតែទទួលដោយពិធីសូត្រធម្ម បង្សុកូល បញ្ជូនកុសល ជារៀងរាល់ពេលដែលមានការវេប្រគេនចង្ហាន់ មុននឹងឆាន់មុខម្ហូបដ៏ច្រើនហៀរតុ ដែលដាក់តម្រៀបពីមុខព្រះសង្ឃនោះ។

នៅតំបន់ឡូវែលនេះ មានគ្រួសារខ្មែរជាង៤ម៉ឺននាក់រស់នៅ គឺជាតំបន់ដ៏សម្បូរខ្មែរបំផុត មករស់នៅឆ្នេរខាងកើតនៃសហរដ្ឋអាមេរិកនេះ គេបាននាំទាំងជីវិត ជីវភាពរស់នៅ ទំនៀមទំលាប់ មករស់នៅជុំគ្នា តាំងពី៣០ឆ្នាំមកហើយ ក៏កើតបានជាក្រុងខ្មែរ ដែលមានហាងម្ហូបអាហារខ្មែរគ្រឿងអលង្ការខ្មែរសំលៀកបំពាក់ខ្មែររហូតដល់វត្តអារាមខ្មែររៀបចំពីធីបុណ្យអុំទូកយ៉ាងឧឡារិក មានទាំងមន្ត្រីជាប់ឆ្នោតជាតំណាងរាស្ត្រជាអភិបាលក្រុងទៀតផង។ កេរដំណែលពីដូនតារាប់ពាន់ឆ្នាំរបស់ខ្មែរ បានធ្វើដំណើរមកដល់សហរដ្ឋបង្កើតបានជាក្រុមរបាំបុរាណ ជាក្រុមជាងចម្លាក់ គំនូរ ភ្លេងនឹងចម្រៀងរៀនអក្សរខ្មែរ គ្រប់បែបយ៉ាងដែលកាលពីជំនាន់ដើម នៅឯកម្ពុជាឯណោះ មានតែវត្តអារាមទេ ជាអ្នកថែរក្សាក្នុងសណ្ឋានជាក្រុមឯករាជ្យមិនសូវចំណុះរដ្ឋបាលណាទេ។ គេនៅតែ

តទៅទំព័រទី ០៩







# វេជ្ជបណ្ឌិត សុខារិទ្ធិ ម៉ី
## DR. SOKHARITH MEY, MD



## ចាប់ផ្តើមទទួលអ្នកជំងឺថ្មី
## ទាំងពីរការិយាល័យឡូវែល & លីន

**Now Accepting New Patients at both Offices**

**Family Medicine & Behavioral Health**

**Please Call Us To Enroll:**

**Lowell - (978) 455-7992**

**Lynn - (781) 780-7755**

ផ្នែកជំងឺទូទៅ និងជំងឺផ្លូវចិត្ត

មណ្ឌលពិនិត្យសុខភាពឡូវែល
**Lowell Primary Care Center**
1075 Westford St. Unit 204
Lowell, MA 01851

មណ្ឌលពិនិត្យសុខភាពលីន
**Lynn Primary Care Center**
280 Union St. Unit 402
Lynn, MA 01901

បុគ្គលិកនិយាយភាសាខ្មែរ/ Staff speak Khmer
We accept MassHealth, Medicare and other health insurances


កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ ១៩៩១
សម្រាប់ប្រទេសកម្ពុជា
ប្រវត្តិសាស្ត្រ និង កេរដំណែល
ថ្ងៃសៅរ៍ ទី ២៧ ខែតុលា ឆ្នាំ ២០១៨
ចាប់ពីម៉ោង ១ រសៀលដល់ម៉ោង ២:៣០ រសៀល
បណ្ណាល័យ O'Leary Library 222 នៃ UMass Lowell
61 Wilder St., Lowell, MA
Cambodia
សាធារណជនអាចចូលរួមកម្មវិធីនេះដោយឥតគិតថ្លៃ
KhmerPost USA
UMASS LOWELL
CAAS@UML.EDU
Center for Asian American Studies


ការដាក់ដេញថ្លៃលក់ទ្រព្យសម្បត្តិ
ប្រភេទផ្ទះវិចផ្លូរៀនពីរគ្រួសារ
222 VARNUM AVE – LOWELL, MA
ថ្ងៃពុធ ទី 31 ខែតុលា វេលាម៉ោង 11 ព្រឹក
នឹងត្រូវលក់ទៅឲ្យអ្នកដេញថ្លៃដែលឲ្យខ្ពស់បំផុតតាមរយៈការបញ្ជាក់របស់អ្នកបាត់ថែងទ្រព្យសម្បត្តិ
ឱកាសដ៏អស្ចារ្យសម្រាប់អ្នកវិនិយោគ និងអ្នកសាងសង់អជីពដែលមានបទពិសោធន៍។
នៅម្ខាងពីច្រកចូលធំទៅកាន់មន្ទីរពេទ្យឡូហ្វែលជេនឌឺរ៉ល (Lowell General Hospital)
រីករាយការជិះឡានក្រុងដោយមានភាពងាយស្រួលនៅកាន់ញ៉ូហាំមស័រ ហ្វ៊ី តាក និងផ្លូវធ្វើដំណើរ
ទិញមកវិញផ្សេងទៀត។
ប៉ុន្មាននាទីប៉ុណ្ណោះពីផ្លូវសម្រាប់អ្នកស្មើរជើងរបស់ម៉ារីម៉ាក់រីវើរ តាមបណ្ដាយផ្លូវ ផាទុកកេត ប៊ូលលីវ័រ
វង់ចាំការជួសជុលកែលំអឲ្យទៅជាគេហដ្ឋានរបស់អ្នក! ស្វាគមន៍ចំពោះការចូលរួមរបស់ឈ្មួញកណ្ដាល
សម្រាប់ព័ត៌មានបន្ថែម និងព័ត៌មានស្ដីពីអចលទ្រព្យនេះ ៖
John McInnis
AUCTIONEERS • APPRAISERS
mcinnisauctions.com
800-822-1417
ការពិនិត្យមុនពេលដាក់ដេញថ្លៃ
ថ្ងៃអាទិត្យទី 21 ខែតុលា វេលាម៉ោង 12 ថ្ងៃត្រង់ដល់ម៉ោង 2 ហើយថ្ងៃអង្គារ៍ ទី23 ខែតុលា ម៉ោង៣
រសៀលដល់ 5 ល្ងាច រឺតាមការណាត់
ថ្ងៃដេញថ្លៃ: ការចុះឈ្មោះចូលរួម បើកទទួលនៅម៉ោង 10 ព្រឹក
លក្ខខណ្ឌ: ដាក់តំកល់ប្រាក់ $20,000 ជាសែកដែលមានការបញ្ជាក់ពីធានាគារដើម្បីអាចចុះឈ្មោះ។
អ្នកទិញត្រូវបង់ព្រីមៀម 10% បន្ថែមលើតំលៃផ្ទះដែលដេញបាន
អជ្ញាប័ណ្ណម៉ាសាជូសេត #770


LEC
LOWELL
EDUCATION CENTER
OPEN
Enrollment
ELECTRONIC ASSEMBLY
រកការធ្វើ-អេឡិចត្រូនិច
NAIL
ធ្វើក្រចក
FACIAL
ថែរសម្ផស្ស
LEARNER PERMIT
អាជ្ញាប័ណ្ណរៀនបើកបរ
CITIZENSHIP
ចូលសញ្ជាតិ-អាមេរិកាំង
MS-WINDOWS & OFFICE
រៀនប្រើកុំព្យូទ័រ
AFTER SCHOOL PROGRAM
បង្រៀនសិស្សបន្ថែម
ESL - CLASS
បង្រៀនភាសាអង់គ្លេស


LEC
LOWELL
EDUCATION CENTER
AFTER-SCHOOL PROGRAM
កម្មវិធីជំនួយសិក្សាក្រោយម៉ោងសាលារៀន
ទទួលឱ្យចុះឈ្មោះចូលរៀនហើយ
THE PLACE TO BE AFTER SCHOOL
After School Program
REGISTER NOW!
After School Program (From 2:30pm - 5:30pm)
- Homework Assistant
- Computer
- Education Games
- Grade: 1- 4
- Kung Fu
- Khmer Language
OFFICE: (978) 459 - 5300 DIRECT: (978) 888 - 8099
325 CHELMSFORD ST. SUITE#1, LOWELL, MA 01851
WWW.LOWELLEC.COM

# New Member Monthly Feature All Care Resources Based in Lynn, Massachusetts

By Soben Pin

In this print, we highlight the All Care Resources' Adult Foster Care. It is a program designed to support patients and their caregivers living together in the community by providing clinical support, education, and financial compensation.



To be eligible for the program, one must:

-Client must be 16 years or older, require caring and supervision with activities of daily living and have Mass Health Standard.

-Caregiver must be at least 18 years old, live in the home and cannot be a spouse, legal guardian of the client or parent of a minor child.

- Caregiver and client must live together and the caregiver must be able to provide 24/7 support as needed. If you are interested, please call Lyna Dep at 781-244-1115 or visit their office at 210 Market St Lynn, MA 01901

# កម្មវិធីថែទាំមនុស្សចាស់នៅលីន

កម្មវិធីថែទាំសុខភាពសម្រាប់មនុស្សពេញវ័យរបស់គម្រោង អល ខែរីសស (All Care Resources) ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីជួយដល់អ្នកជំងឺ និងអ្នកថែទាំដែលរស់នៅជាមួយគ្នានៅក្នុងសហគមន៍ តាមរយៈការផ្តល់នូវការគាំទ្រផ្នែកវេជ្ជសាស្ត្រ, ការអប់រំ និងប្រាក់កម្រៃ។

ដើម្បីមានសិទ្ធិទទួលជំនួយពីកម្មវិធីនេះ លោកអ្នកត្រូវ :

-អ្នកជំងឺអាយុ១៦ឆ្នាំនិងច្រើនជាងនេះ ហើយត្រូវការការថែរក្សា និងការមើលការខុសត្រូវសម្រាប់សកម្មភាពនៃការរស់នៅប្រចាំថ្ងៃ និងត្រូវមានស្តង់ដាម៉ាស់ហែល។

-អ្នកថែទាំត្រូវមានអាយុយ៉ាងហោចណាស់ ១៨ឆ្នាំ រស់នៅក្នុងផ្ទះជាមួយនឹងអ្នកជំងឺ តែអ្នកមើលថែនោះមិនត្រូវជាប្រពន្ធ រឺស្វាមី, អ្នកទទួលសិទ្ធជាអាណាព្យាបាលស្របច្បាប់របស់អ្នកជំងឺ ឬជាឪពុកម្តាយដែលមានកូនមិនទាន់ពេញវ័យនោះទេ។

-អ្នកថែទាំ និងអ្នកជំងឺត្រូវតែរស់នៅជាមួយគ្នា ហើយអ្នកថែទាំត្រូវតែមានលទ្ធភាពមើលថែអ្នកជំងឺពេញ២៤ម៉ោងក្នុង៧ ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍ សូមទំនាក់ទំនង លីនា ឌៀប (Lyna Dep) តាមរយៈលេខទូរសព្ទ ៧៨១-២៤៤-១១១៥ រឺមកកាន់ការិយាល័យរបស់យើងខ្ញុំតាមរយៈអាស័យដ្ឋាន 210 Market St Lynn, MA 01901 ។

# ខ្យល់ព្យុះកំណាច"ម៉ាយខិល"

ខ្យល់ព្យុះ"ហ្គូរីខេន"ឈ្មោះ ម៉ាខិល បក់មកពីសមុទ្រអាត់ឡង់ទិកក្នុងល្បឿន១៥៥ម៉ាយក្នុង១ម៉ោង បានបក់មកដល់ជ្រោយរដ្ឋ"ផ្លរីដា"នាថ្ងៃពុធនេះ ជាខ្យល់ព្យុះក្នុងកម្លាំងបក់កំរិត៤ ដែលអាចផ្តល់ការគ្រោះថ្នាក់កំរិតខ្ពស់ដល់កន្លែងដែលខ្យល់នេះបក់ប៉ះវានឹងធ្វើឱ្យអន្តរាយដល់ផ្ទះសម្បែង នឹងជីវិតមនុស្សសត្វទៀតផង។




លោកប្រធានាធិបតី ឌុណល ត្រម បានប្រកាសភាពអាសន្នដោយសារខ្យល់ព្យុះមួយនេះ ដោយបញ្ជូនកងការពារក្នុងគ្រោះមហន្តរាយចំនួន ២៥00នាក់ ទៅជួយពលរដ្ឋផ្លរីដា នឹងអញ្ជើញឱ្យពលរដ្ឋគេចចេញពីកន្លែងមានភ័យអាសន្នជាមណ្ណោះអាសន្នភ្លាមផង។ រៀងរាល់ឆ្នាំតំបន់"រដ្ឋផ្លរីដា"នេះ តែងជួបប្រទះគ្រោះខ្យល់ព្យុះជាញឹកញយ កាលពីឆ្នាំមុនខ្យល់ព្យុះកំណាចបានបំផ្លាញទ្រព្យសម្បត្តិនឹងដំណាំដាំដុះដល់តម្លៃច្រើនលានដុល្លារ តែឆ្នាំនេះក៏រដ្ឋផ្លរីដា នៅតែមិនមានសមត្ថភាពពេញខ្លួនសម្រាប់កាពារពលរដ្ឋខ្លួនឯងនៅឡើយទេ។




តមកពីទំព័រទី ០១

## ក្រុមសិល្បៈសមាគមអង្គរចេញ...

"វិទ្យាល័យឡូវែល"រៀបចំឡើងដោយសមាគមអង្គរ ដើម្បីរកថវិការទ្រទ្រង់សមាគម។ ឆាកទស្សនីយភាពចាប់ផ្តើមនៅម៉ោង៧,៣០យប់ ជាមួយនឹងសាធុកា រួចបួងសួងដល់ម្ចាស់ទឹកម្ចាស់ដីសុំឱ្យជួយដល់ការសម្តែងរបស់សិល្បករឱ្យប្រកបដោយជោគជ័យវាជាផ្នែកមួយដែលល្ខោននឹងសិល្បៈបូរាណនឹងប្រពៃណីខ្មែរមិនដែលខកខាននឹងធ្វើឡើយ។

សិល្បៈករនៃក្រុមសមាគមអង្គរនេះ មានចំណាស់៣២ឆ្នាំហើយ "កូនណោង"ប្រមាណ ១០០នាក់ ទាំងអស់សុទ្ធសឹងតែបានហាត់ហ្វឹកហ្វឺនវិជ្ជាសិល្បៈខ្មែរនេះ ពីលោកគ្រូនឹង-អ្នកគ្រូដែលបានសិក្សាចេញពីសាកលវិទ្យាល័យវិចិត្រសិល្បៈ នាទីក្រុងភ្នំពេញ ហើយក៏ធ្លាប់ចេញសម្តែងជាច្រើនដងរួចមកហើយ ដែរ ហេតុនេះហើយ បានជាស្នាដៃសិល្បៈបូរាណខ្មែររបស់សមាគមនេះ មានកេរឈ្មោះព្យល្បីពេញតំបន់"ញូឥនគ្លិន"ជាច្រើនឆ្នាំមកហើយដែរ ។ នៅលើកនេះជាថ្មីម្តងទៀត ឆាករបាំជូនពរ បន្ទាប់មកឆាកល្ខោនរឿង "មុនីមេខលា" គឺជារបាំប្រពៃណី ឬក៏ហៅថា "របាំព្រះរាជទ្រព" ដែលទាំងសំពត់អាវគ្រឿងអលង្ការភ្លឺដូចមាសទឹក១០ទាំងកាយវិការក្បាច់ បានធ្វើឱ្យឆាកល្ខោនក្លាយជាវេទិការរៀបចំឡើងដូចជាសម្តែងសម្រាប់ព្រះមហាក្សត្រ

តទៅទំព័រទី១០

នាជំនាន់ដើមបាន -ទាំងនេះ គួបផ្សំនឹងគុណសម្បត្តដូរ្យតន្ត្រីជាមួយមហាវិទ្យាល័យ "ទូហ្វ" នឹងការប្រើបច្ចេកទេសបញ្ចាំងភ្លើងពណ៌នឹងសម្លេងរបាំបូរាណខ្មែរត្រូវគេពិពណ៌នាថា"ជារបាំមានមហិទ្ធិរិទ្ធ"២នោះទំនងជាមិនខុសទេ។


នាង មុន្នីមេខឡា

នៅមានការសម្តែងរបាំឆាកប្រជាប្រិយ ជាទំនៀមទំលាប់ខ្មែរ ជាពលរដ្ឋប្រទេសដែលសប្បូរទឹកភ្លៀង កុមារសិល្បករកូនក្អាត់



កូនកញ្ចាញ់ចេក លោតប្រសេចប្រសាចប្រឹងគេចពីកណ្តាប់ដៃក្រុមអ្នកនេសាទដ៏ស្រេកឃ្លានធ្វើឱ្យទស្សនិកជនទប់សំណើចមិនបាន, ក្រៅពីនេះ មានអ្នកនេសាទវ័យជំទង់ឆ្លៀតពេលមានក្រមុំស្អាតៗ មករកនេសាទដូចគ្នាតាមចែចង់គេតាមទំនៀមទំលាប់អ៊ឹមអៀមលាក់លៀម ជាកូនខ្មែរអ្នកស្រែចំការ មិនសូវមានឱកាសមានមិត្រភក្ត្រខុសភេទគ្នា ធ្វើឱ្យទស្សនិកជនពិបាកយល់ពីឥរិយាបទទំនាក់ទំនងស្រីប្រុសខ្មែរដ៏ស្រទន់ផ្អែមល្ហែមបន្តិចដែរ។

សមាគមអង្គរបើកសម្តែងទស្សនីយភាពលើកនេះ ធ្វើជា២រាត្រី គឺរាត្រីសុក្រទី៥នឹងសៅរ៍ទី៦នេះ ដោយមានក្រុមជាជំនួយការគ្រប់ផ្នែកប្រមាណ១០០នាក់ ក្រោមការដឹកនាំរបស់លោកប្រធាន ម៉ាយខិល ខនវ៉េយ នឹងស្ថាបនិក ធីម ធូ ។ មានភារកិច្ចថែរក្សាវប្បធម៌ខ្មែរឱ្យបានគង់វង្សនៅឯស្រុកអាមេរិក សមាគមអង្គរ បានបណ្តុះបណ្តាល ថ្នាលសិល្បៈរបស់ខ្លួន បានច្រើនរយនាក់ហើយ នឹងចេញសម្តែងបានច្រើនឆ្នាំមកហើយ, មានអង្គការជាច្រើនទៀត បានចូលមកគាំទ្រសកម្មភាពដើម្បីវប្បធម៌ខ្មែរនេះ មានជាអាតិធានាគារ"ឥធីប្រាយបេង" មាន"សឹកខិលហ៊ែល" មានធានាគារ"ស្ពានដាក" មាន"ខនវ៉េយធានារ៉ាប់រង"មាន"ខលវ៉ាចឆរ នឹងខាវ៉ាណ៍រ"។ល។...នៅមានទៀត, រីឯបងប្អូនខ្មែរ អាចគាំទ្រ ដោយនាំកូនចៅឱ្យទៅរៀនចំណោះជាវប្បធម៌ខ្មែរឱ្យបានច្រើនគ្នា។

តមកពីទំព័រទី ០២

## បាតុកម្មប្រឆាំងនឹងវត្តមាន ហ៊ុន សែន

ប្រមាណជា១០%ប៉ុណ្ណោះ ដែល នៅនឹង-កន្លែង ពីព្រោះតែលោកមានទម្លាប់និយាយ ផ្ទុយ-ពីការពិត យ៉ាងជាក់ស្តែង ដូចជាលោកថ្លែងថា "ព្រៃឈើវិនាសដោយសាររាស្ត្រត្រូវការដី..."ឬក៏ "ហាមមិនឱ្យបរទេសលូកដៃកកូរផ្ទៃក្នុងរបស់កម្ពុជាក្នុងនាមនៃសិទ្ធមនុស្ស..."។ លោក ហ៊ុន សែន បានទទួលស្គាល់នៅពេលដែលមានគេសួរថា តើពិតឬទេដែលថា អាមេរិក គេវ៉ាស់ដីឱ្យលោកដើរមែនឬទេ? លោកបានឆ្លើយថា"មែន"ពីព្រោះលោកចុះពីយន្តហោះ មកសណ្ឋាគារ ចេញពីសណ្ឋាគារមក "យូអិន"តែប៉ុណ្ណោះ។

ប៉ុន្តែមុននេះបន្តិច លោកស្រី រូណា ស្មីត ប្រេសិទ្ធអ.ស.ប.ប្រចាំប្រទេសកម្ពុជាបានធ្វើសេចក្តីរាយការលំអិតមួយស្តីពីការរំលោភសិទ្ធិមនុស្ស សិទ្ធិនយោបាយរំលោភសេរីភាពសារព័តិមាន រំលោភសិទ្ធដីធ្លី...។ល។ នៅកម្ពុជារួចជាស្រេច... ដែលធ្វើឱ្យគេមើលឃើញថា សុន្ទរកថា លោកនាយករដ្ឋមន្ត្រីខ្មែរដ៏មានអំណាចគ្រាន់តែមកសម្តែងឆាកល្ខោន ដ៏កំសត់មួយ ដែលគ្មាននរណាសើចយំនឹងរឿងរបស់លោកបានបន្តិចណានោះទេ..." ពីព្រោះលោកធ្វើនោះ សម្រាប់តែបង្ក្រាបប្រជាពលរដ្ឋខ្មែរដែលគ្មានព័តិមានពិតនៅក្នុងប្រទេសឱ្យខ្លបខ្លាចអំណាចរបស់គាត់តែប៉ុណ្ណោះ ។ ចុះក្រុមដែលគាំទ្រលោក ហ៊ុន សែន មានតួនាទីអ្វីទៅ?

នៅប្រទេសប្រជាធិបតេយ្យក្រុមបាតុករដែលគេចេញមកសម្តែងឆន្ទៈ គឺជាក្រុមដែលឯករាជ្យមកសម្តែងឆន្ទៈយ៉ាងសេរី ទើបយកជា"បានការ" ក្រុមនោះ គឺជាអ្នកប្រឆាំងនឹង"ហ៊ុន សែន" គេចំណាយលុយដែលខ្លួនឯងរកបានលើថ្លៃឡានលើថ្លៃម្ហូបអាហារលើពេលវេលាដែលចំណាយសម្រាប់ធ្វើដំណើរទៅមកនឹងធ្វើបាតុកម្ម, មានខ្លះមិនបានមកធ្វើបាតុកម្មនឹងគេ ក៏ជួយជាសោហ៊ុយ ដែលគ្មានចំណងចំពោះអ្នកដែលមានឆន្ទៈដូចគ្នាជួយឱ្យមានចំណាយកាន់តែតិច ។ វាផ្ទុយគ្នាពីក្រុមមកសសើរពី"ហ៊ុន សែន"ជិះយន្តហោះ"ហ៊ុន សែន" ឬជិះប៊ីស"ហ៊ុន សែន"ដេកក្នុងសណ្ឋាគារ"ហ៊ុន សែន" ទទួលអំណោយពី ហ៊ុន សែន" ឆន្ទៈនៃក្រុមនោះ គេ"មិនយកជាបានការទេ"ទោះជាអ្នកឯងស្រឡាញ់ឬស្អប់ក៏ដោយ ពួកគេគ្រាន់តែជាក្រុម"ទេសចរ" តែប៉ុណ្ណោះ ។ លោក ហ៊ុន សែន បានដឹងពីគោលការ"សំដែងឆន្ទៈ"របស់គ្នាគាត់យ៉ាងច្បាស់លាស់ណាស់ ថាវា"មិនយកថាជាការសម្តែងឆន្ទៈបានទេ" ហេតុនេះហើយបានជាយើងថា លោក ហ៊ុន សែនគ្រាន់តែជាអ្នកសម្តែងល្ខោនឱ្យខ្មែរក្នុងស្រុកមើលតែប៉ុណ្ណោះ។



តមកពីទំព័រទី ០៤

# ពិធីបុណ្យកាន់បិណ្ឌនៅឡូវែល...

សង្ឃឹមនៅឡើយថា"វត្តអារាមនៅសហរដ្ឋនេះ នឹងមានទទួលមុខងារបន្ថែមពីការរក្សាសាសនាព្រះពុទ្ធ គឺៈ រក្សាវប្បធម៌ខ្មែរ ដូចគ្នានឹងជំនាន់ដើមដែរ" ដែល"វត្តពន្លឺពុទ្ធចក្រ"នៅឡូវែល បាននាំមុខជាគំរូខាងបង្រៀនភាសាខ្មែរដល់ក្មេងៗរួចហើយ។

"វត្តសាមគ្គីសន្តិការរាម"ដ៏ថ្មីច្រឹងនេះ ទើបនឹងបែកចេញពី"វត្តត្រៃរតនារាម"មិនបាន៣ឆ្នាំផងក៏សង់បានវត្តថ្មីនេះឡើង, ឆ្នាំនេះបានប្រកាសថា ទិញដីជាប់គ្នានោះបានថែមទៀត ក្នុងតម្លៃ៤៥ម៉ឺន។ ពុទ្ធបរិស័ទបានត្រូវអញ្ជើញឱ្យចូលចាប់កុសលក្នុងតម្លៃ២៣២ដុល្លាក្នុង១ម។ ក្រឡានេះ គឺជាដំណឹងដ៏គួរឱ្យរីករាយមួយដែលការព្យាយាមនឹងសីលធម៌ បានចេញបានជាផ្លែផ្កាបានស្រស់បំព្រង

-នាព្រឹកបិណ្ឌទី១០នោះ មានគ្រួសារមួយមានគ្នា៥នាក់ បានរួមចំណែកចាប់កុសលទិញដី១ម។ ដើម្បីឧទ្ទិសដល់"អស់បុព្វបុរស"ដែលបានលា លោកទៅហើយ ដើម្បីជាការតបស្នងសងគុណ នឹងជាការនឹករលឹកដល់ស្នាដៃដែលបានកសាងចំពោះបុគ្គលផ្ទាល់ខ្លួន ចំពោះគ្រួសារផង - បុព្វបុរសខ្លះទៀតក៏មានស្នាដៃធំធេងចំពោះកិច្ចការពារប្រទេសជាតិរបស់ខ្លួន ដូចជាលោក ស៊ឹម វ៉ា លោក សឹង សាន លោក អៀវ កឹស លោក កេង វ៉ាន់សាក់ លោក លន់ នល់ សម្តេច ជួន ណាត នឹងសម្តេច សីហនុ ព្រះបាទជ័យវរម្ម័នទី៧នឹងព្រះនាងឥន្ទ្រទេវី... ។ល។ សូមឱ្យលោកអ្នកទាំងនោះ ជួបតែនឹងសុគតិភព ហើយនៅតាមបន្តថែរក្សាប្រទេសកម្ពុជាឱ្យបានគង់វង្សជារៀងរហូតតទៅ។




ពិធីរាប់បាត



ក្រឡាថ្មីទៀត សម្រាប់ដាក់វត្ត។

ដូចបុណ្យជាច្រើនដែលប្រារព្ធដើម្បីជំនឿថា "មានបុព្វបុរសដែលបានចែកឋានទៅហើយ ត្រឡប់មករកគ្រួសារវិញ" មានបុណ្យ "ទូសាំង" នៅប្រទេសបារាំងនឹងអឺរ៉ុប មានបុណ្យ"ហាឡូវីន" មានបុណ្យ"Thankgiving ថែងគ្គីវីង"នៅអាមេរីក មានបុណ្យ"សែនក្បាលទឹក"នៅចិន... គេតែងទៅដាក់កម្រងផ្កានៅផ្នូរខ្មោច សែនចំណីអាហារនៅផ្ទះ, រីឯបុណ្យ"ភ្ជុំបិណ្ឌ"គេប្រគេនចង្ហាន់នៅវត្ត


កម្មវិធីថែទាំសុខភាពសម្រាប់មនុស្សពេញវ័យរបស់គម្រោង អល ខែរីសស (All Care Resources) ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីជួយដល់អ្នកជំងឺ និងអ្នកថែទាំដែលរស់នៅជាមួយគ្នានៅក្នុងសហគមន៍តាមរយៈការផ្តល់នូវការគាំទ្រផ្នែកវេជ្ជសាស្ត្រ, ការអប់រំ និងប្រាក់កម្រៃ។

លក្ខខណ្ឌនៃការដាក់ពាក្យក្នុងកម្មវិធីនេះ :

-អ្នកដែលមានជំងឺត្រូវមានអាយុ១៦ឆ្នាំនិងច្រើនជាងនេះ ហើយត្រូវការការថែរក្សានិងការមើលការខុសត្រូវសម្រាប់សកម្មភាពនៃការរស់នៅប្រចាំថ្ងៃ និងត្រូវមានស្តង់ដាម៉ាស់ហែល។

-អ្នកថែទាំត្រូវមានអាយុយ៉ាងហោចណាស់១៨ឆ្នាំ រស់នៅក្នុងផ្ទះជាមួយនឹងអ្នកជំងឺតែអ្នកមើលថែនោះមិនត្រូវជាប្រពន្ធ រឺស្វាមី, អ្នកទទួលសិទ្ធជាអាណាព្យាបាលស្របច្បាប់របស់អ្នកជំងឺ ឬជាឪពុកម្តាយដែលមានកូនមិនទាន់ពេញវ័យនោះទេ។

-អ្នកថែទាំ និងអ្នកជំងឺត្រូវតែរស់នៅជាមួយគ្នា ហើយអ្នកថែទាំត្រូវតែមានលទ្ធភាពមើលថែអ្នកជំងឺពេញ២៤ម៉ោងក្នុង៧ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើអ្នកមានចំណាប់អារម្មណ៍ សូមទំនាក់ទំនង លីនា ឌៀប (Lyna Dep) ដែលស្ទាត់ជំនាញភាសាខ្មែរ តាមរយៈលេខទូរស័ព្ទ ៧៨១-២៤៤-១១១៥ ។



**KhmerPost USA, LLC**

**សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក**

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852

លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092

អ៊ីម៉ែល info@khmerpost.us

អានកាសែតនៅគេហទំព័រ www.khmerpost.us

ផ្សាយពាណិជ្ជកម្ម Advertising

អគ្គនាយក សុបិន្ត ពិន Soben Pin, *Co-Founder/Publisher*

លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)

អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ Editorials

និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Co-founder/Editor*

(978) 942 - 1641 | rogerpin@khmerpost.us

ការិនិពន្ធ Staff Writers:

អ្នកនិពន្ធកិត្តិយស Staff Writer/Translator

Sokharath Koy

ច្នៃសោភ័ណភាពកាសែត Design Artist

Heng Chhunleng

ជំនួយការរដ្ឋបាល Office Coordnator

Sochet Chhen

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

Follow us: Facebook | Twitter KhmerpostUSA



ការិយាល័យ មេធាវី

ថំមាស ស្តាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**

**287 Appleton St. Lowell MA 01852**

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

www.thomasinlowell.com

# A Panel Discussion on History and Legacy of Cambodia's 1991 Paris Peace Accords Will Be Held at UMASS Lowell

By KhmerPostUSA

On Saturday, October 27 - a panel discussion on the history and legacy of Cambodia's 1991 Paris Peace Accords will be held at O'Leary Library 222, University of Massachusetts Lowell at 61 Wilder Street. It is scheduled from 1pm - 2:30pm. It is free and open to public.

This year marks the 26th anniversary of an important event that affected Cambodia. Formally titled Agreements on a Comprehensive Political Settlement of the Cambodia Conflict, the 1991 Paris Peace Accords launched a process of cease-fire, peacekeeping and rebuilding that stabilized the country, but left deep wounds still unhealed from the 1970s genocide and decades of war. The Cambodian peace process was one of the first of its scale undertaken by the international community after the Cold War—and over twenty seven years of work to implement it offers lessons for current and future peacebuilding work, both in Cambodia and worldwide.

The event will feature two speakers below:

Retired General Chheang Mam was former Vice-Chairman of the Joint Chiefs of Staff of the Royal Cambodian Armed Forces and Head of the Department of International Relations of the Cambodian Ministry of National Defense. During the Cambodian peace process. Ret. Gen. Mam travelled to seek support for the peace agreement from international communities and allied countries, and he was a member of the Working Group of the Paris Conference on Cambodia (1989, first session) as well as of the First Committee (Military Matters) of the Paris Conference (1991, second session). A former member of the resistance movement against the Khmer Rouge and President of the Phnom Dangrek Refugee Camp at the Thai-Cambodia border, Ret. Gen. Mam now resides in Lowell, MA.




Professor Sophal Ear, Ph.D., is an Associate Professor of Diplomacy & World Affairs at Occidental College in Los Angeles where he teaches international political economy, international development, international security, and Asian security. Previously, he taught at the U.S. Naval Postgraduate School and the Maxwell School of Syracuse University. He has consulted for the World Bank, was Assistant Representative for UNDP in East Timor, and served as Advisor to Cambodia's first private equity fund Leopard Capital. He is the author of Aid Dependence in Cambodia: How Foreign Assistance Undermines Democracy (Columbia University Press) and co-author of The Hungry Dragon: How China's Resources Quest is Reshaping the World (Routledge). A graduate of Princeton and Berkeley, he moved to the United States from France as a Cambodian refugee at the age of 10.

This event is cosponsored by the UMass Lowell Center for Asian American Studies and the Cambodian Mutual Assistance Association of Lowell.

Parking is free & available at the Wilder Faculty & Staff parking lot, across the street from O'Leary. For further information, please contact CAAS@uml.edu.






## ផ្តើមសេចក្តី

អារម្ភកថា

យើងសូមជូនរឿងថ្មីមួយទៀត គឺរឿង"កុមារ យោធិន្ទ"ជាប្រវត្តិកុមារប្រមាណជា១ពាន់នាក់ ដែលបានចូលទៅបំរើក្នុងកងទ័ពតាំងពីអាយុ១០ឆ្នាំ នៅសាលារៀនមួយដែលកងខេមរភូមិន្ទបាន បង្កើតឡើងបន្តពីអាណានិគមបារាំងក្នុងបំណងជួយចិញ្ចឹមកូនរបស់កងទ័ពបង្ហាត់បង្រៀនមុខវិជ្ជាដែល ឪពុករបស់គេស្រឡាញ់ចូលចិត្តនឹងបានបូជាជីវិត ដើម្បីមាតុភូមិរបស់គេថែមទៀត។

ជារឿងពិតរបស់យុវជនមួយក្រុមរស់នៅដាច់ពីការថ្នាក់ថ្នមរបស់ឪពុកម្តាយមិនដូចក្មេង ឯទៀត គេចិញ្ចឹមកុមារទាំងនោះ ក្រោមវិន័យតឹងរឹងនៃកងទ័ពបង្ហាត់ហ្វឹកហ្វឺននឹងរៀនសូត្រវិជ្ជាចម្បាំងតាំងតែពីនៅតូច តែសាធារណជនមិនសូវដែលដឹងថា"សាលានោះជាអ្វី? បង្ហាត់បង្រៀនរបៀបណា? នឹងស្គាល់ថា ជាអ្វីនោះទេ" ក្រៅតែពីអ្នកនៅក្នុងក្រុងជាមួយនឹងអ្នកមិនឆ្ងាយពីបន្ទាយនៃកូនទាហ៊ានទាំងនោះ តែប៉ុណ្ណោះដែលស្គាល់ ហើយឱ្យឈ្មោះថា"ពួកក្មេងហ្វូង" ដែលជាឈ្មោះបកប្រែពីពាក្យបារាំងមកថា"Les enfants de troupe"។

# សាលាកងកុមារយោធិន្ទការមកដល់នៃសិស្សថ្មី (ត)

**ពិន សំខុន**

**ភាគ១ - សាលាកងកុមារយោធិន្ទ ការមកដល់នៃសិស្សថ្មី (ត)**

នៅសាលាកុមារយោធិន្ទ ក៏មានរឿងគួរឱ្យខ្លាចមួយចំនួនបានកើតឡើង ជាមួយនឹងការគ្រប់គ្រងរបស់លោកមេបញ្ជាការគឺអនុសេនីយទោ ទឹម ថូ លើក្រុមព្រះក្សត្រានៃព្រះរាជវង្សខ្លះដែរ ដូចជាព្រះអង្គម្ចាស់នរោត្តម យុវនាថ ជាដើម។ នៅកំពង់ចាម ព្រះអង្គម្ចាស់បានឃើញសម្ផស្សនាងកញ្ញាសាច់សស្អាត នៅក្មេងខ្ចី តូចទាបស្រស់បស់ ជាកូនស្រីនៃម្ចាស់ហាងលក់សៀវភៅនៅមាត់ទន្លេកំពង់ចាម ក៏ចាប់ចិត្តស្រឡាញ់គេគ្មានឈប់ឈរ, នាងនោះមានឈ្មោះថា កញ្ញា"ទាគិម យិន" -ព្រះអង្គមានមិត្តភក្រ្តសមគំនិតកុមាយោធិន្ទ២-៣នាក់ ដែលមានគ្រែនៅជិតគ្នាមាន ទេព ប៉ាល់ មាន ពិន សំផុន មានមាច ជំនិត ។ល។ គាំទ្រការលាក់អាថិកំបាំងនេះ តែក៏លាក់មិនជិតទេ ដោយព្រះអង្គតែងតែទៅលួចមើល នាងនោះពេលគេចេញពីថ្នាក់ទៅហាត់ប្រាណ ឬពេលគេនាំគ្នាជិះកង់ត្រសងចេញពីរៀន នាពេលម៉ោង៥ល្ងាច ពីវិទ្យាល័យព្រះសីហនុជាញឹកញាប់ធ្វើឱ្យ នាងគិមយិនដឹងខ្លួនហើយខ្មាសអៀនជាអាណែក -មានពេលខ្លះព្រះអង្គម្ចាស់ ធ្វើជាទៅរកទិញសៀវភៅក្នុងនៅឯបណ្ណាល័យឪពុកនាងតែម្តង ដោយសង្ឃឹមថា នាងនឹងចេញមកទទួលភ្ញៀវ តែគេដឹងខ្លួនពីបំណងមិនល្អនេះ នាងមិនដែលចេញមកជួបព្រះអង្គម្ចាស់ម្តងណាទេ ។

ព្រះអង្គតែងលួចចេញពីបន្ទាយស្ងាត់ៗ ដើម្បីរកឱកាសបានឃើញរូបនាងកញ្ញា គិម យិន លបមើលគេនៅបង្អួចផ្ទះជាន់លើរបស់នាង ក្រែងបានឃើញបន្តិចក៏អស់ចិត្តដែរ, ច្រើនខែក្រោយមក នៅថ្ងៃមួយនោះ នៅពេលដែលព្រះអង្គចេះលួចចេញទៅក្រៅបន្ទាយ ដោយមិនមានសុំច្បាប់ តែចេះតែមិនមានអ្វីកើតឡើងនោះ ព្រះអង្គក៏នឹកភ្នកចង់ទៅលេងភ្នំពេញម្តងដូច្នេះទោះជាមិត្តភក្រ្តឃាត់ក៏មិនស្តាប់ គ្មានលុយនៅនឹងខ្លួន ក៏លួចជិះកាណូតនៅមាត់ទន្លេសំដៅទៅភ្នំពេញតែមួយអង្គឯង នាកណ្តាលអាធ្រាត្រនៃថ្ងៃសុក្រ ដោយសង្ឃឹមថានឹងត្រឡប់មកដល់បន្ទាយវិញនារសៀលថ្ងៃអាទិត្យ (កាណូតចេញដំណើរទៅភ្នំពេញនាកណ្តាលយប់ តែភ្លឺឡើងក៏ទៅដល់មុខវាំងតែម្តង បើទោះជាមានលុយតិចតួចក៏ទៅបានដែរ ពេលនោះមានលុយ១០រៀលក្នុងហោប៉ៅសម្រាប់ធ្វើដំណើរ) ហើយពេលចុងសប្តាហ៍ដូច្នេះ តែងតែមិនសូវមានការត្រួតពិនិត្យចំនួនសិស្សតឹងតែងនៅសាលាទេ។ តែការស្មានរបស់ព្រះអង្គនេះ មិនបានសមប្រកបទេ ពីព្រោះតែមានអ្នកព្រួយបារម្ភពីសុវត្ថិភាពរបស់ព្រះរាជបុត្រព្រះមហាក្សត្រ ក៏មានអ្នកយករឿងសម្ងាត់នេះទៅប្រាប់ដល់លោក"កុម្មងដង់"ទឹម ថូដែលចេញបញ្ជាជាបន្ទាន់ឱ្យចាប់អ្នកសមគំនិតទាំងអស់យកទៅដាក់គុកទាំងអស់ ពិន សំផុន ទេព ប៉ាល់ -មាជ ជុំនិត ... ។

ល្ងាចថ្ងៃអាទិត្យ ពេលព្រះអង្គម្ចាស់យុវនាថ ត្រឡប់មកដល់បន្ទាយវិញ ដោយមានគេជូនតាមរថយន្តតូចពីភ្នំពេញមកចូលមកដល់ក្នុងបន្ទាយ ស្រាប់តែរកមិត្តភក្តិមិនឃើញបានត្រូវកុមាយោធិន្ទឯទៀត៧ទូលព្រះអង្គថា"អ្នកជូនដំណើរព្រះអង្គម្ចាស់ទាំងប៉ុន្មាន ឥឡូវជាប់គុកអស់ហើយ..." ដូច្នេះមានរឿងហើយតើ? ព្រលប់បន្តិចហើយ ព្រះអង្គក៏ដើរសំដៅទៅបុស្តិ៍ប៉ូលីស(ទិប្រចាំការក្នុងបន្ទាយ) ព្រះអង្គក៏សួរទៅសែពប៉ុស្តិ៍ថា"ហេតុអ្វីក៏ដាក់គុកអ្នកគ្មានកំហុសអ្វីអីចឹង? ខ្ញុំទេតើដែលមានកំហុសនោះ!"សែពប៉ុស្តិ៍អេស


ព្រះអង្គម្ចាស់យុវនាថអតីតកុមារយោធិន

អុញហើយតបដោយទំនងជាខ្លាចអំណាចព្រះអង្គម្ចាស់ថា"នេះជាបញ្ជាលោកកុម្មងដង់បានជាដាក់គុកយ៉ាងនេះ!"ព្រះអង្គម្ចាស់ក៏ឆ្លើយទៅវិញថា"បើអីចឹងដាក់គុកខ្ញុំដែរទៅ! "រឿងក៏វារីតតែធំ តើនរណាហ៊ានដាក់គុកព្រះអង្គម្ចាស់នោះក៏និយាយតបថា" មិនបានទេព្រះអង្គ គ្មានបញ្ហាទេ!"ព្រះអង្គម្ចាស់ក៏បន្តថា" បើអីចឹងទៅបើកទ្វារគុកមក ខ្ញុំនឹងចូលដោយខ្លួនឯង លោកមិនចាំបាច់មានបញ្ហាទេ!"ព្រះអង្គម្ចាស់ក៏សង្ងើញ បង្គាប់ឱ្យបើកទ្វារគុកទាល់តែបាន ហើយចូលគុកខ្លួនឯងមែនធ្វើឱ្យអ្នកនៅក្នុងគុកស្រាប់នោះ រីករាយផងហើយក៏ភ័យផងដែរដែលមានរឿងកូនស្តេចផែនដីមកជាប់គុកជាមួយពួកខ្លួនដែរ វាមិនដែលមានទេ...។ ពេលនោះយប់បន្តិចហើយប្រហែលជាលោកកុម៉ងដង់មិននៅ ឬក៏លោកចង់ទុកក្នុងគុក១យប់ក៏មិនដឹងព្រះអង្គម្ចាស់ត្រូវនៅក្នុងគុករហូតដល់ភ្លឺ ជាមួយនឹងអ្នក៣នាក់ទៀតជាគូរកន។

ម៉ោង៦ព្រឹក គេបានដោះលែងអ្នកទាំងអស់ដើម្បីឱ្យរៀបខ្លួនទៅរៀន ចំណែកលោកកុម៉ង់ដង់បានមកដល់ការិយាល័យរបស់លោកនៅម៉ោង៨ក៏បញ្ជាទាហ៊ានឱ្យនាំព្រះអង្គម្ចាស់មកជួប, លោក"ស៊ែហ្សង់សែព"ស៊ីម បាននាំព្រះអង្គម្ចាស់មកដល់ការិយាល័យកុម្មង់ដង់ ហើយទាំង២នាក់គំនាប់មេបញ្ជាការ ហើយលោកស៊ីមក៏ចេញទៅវិញទុកឱ្យព្រះអង្គម្ចាស់នៅដោះស្រាយតែឯង ជាមួយលោកស័ក្តិពីរ ទឹម ថូ លោកកុម្មង់ដង់អង្គុយនៅតុរបស់លោក ហើយប្រញាប់សួរថា"ព្រះអង្គហេតុអ្វីក៏ចេញទៅណាមិនសុំច្បាប់អីចឹង ដឹងថាមានកំហុសដែរឬទេ?" ព្រះអង្គម្ចាស់ យុវនាថ ដោះបេរ៉េក្រហមពីក្បាលហើយឆ្លើយតបថា "ខ្ញុំដឹងថា ខ្ញុំធ្វើនេះខុសហើយ តែហេតុអ្វីក៏លោកកុម៉ង់ដង់ ដាក់គុកដល់អ្នកដ៏ទៃដែលមិនមានកំហុសអីជំនួសខ្ញុំ?" លោកកុម៉ងដង់ឆ្លើយតបថា"អ្នកជូនដំណើរព្រះអង្គក៏មានកំហុសដែរ ពីព្រោះលួចចេញក្រៅបន្ទាយផង នឹងមិនបានឱ្យខ្ញុំដឹងថា ព្រះអង្គចេញទៅភ្នំពេញផង...តើព្រះអង្គម្ចាស់ដឹងទេថា បើព្រះអង្គមានរឿងអ្វីតាមផ្លូវទៅនោះ តើមិត្រភក្រ្តព្រះអង្គទាំងអស់នោះ នឹងរួចខ្លួនដែរឬទេ? "ព្រះអង្គម្ចាស់យុវនាថតបវិញថា" ខ្ញុំជាអ្នកខុសសុំលោកដាក់ទោសខ្ញុំតែម្នាក់ឯងចុះ កុំដាក់ទោសអ្នកឯទៀតធ្វើអ្វី អ្នកទាំងនោះបានឃាត់ខ្ញុំដែរខ្ញុំពុំបានស្តាប់តាមពួកគេទេ! "លោកកុម៉ងដង់បញ្ជប់ថា" ព្រះអង្គបានដាក់ទោសខ្លួនឯងរួចហើយ ទូលបង្គំមិនចាំបាច់ដាក់ថែមទៀតទេ ឱ្យទេព្រះអង្គដឹងខ្លួនឯងថាបានធ្វើខុសទៅបានហើយ រីឯអ្នកឯទៀតគេក៏បានទទួលទោសរួចហើយដែរ...ទូលបង្គំចង់ដឹងដែរថា តើព្រះអង្គទៅភ្នំពេញមានការអ្វីជាបន្ទាន់ដែរឬទេ?"ព្រះអង្គម្ចាស់តបថា"មិនជាបន្ទាន់ទេតែជាការផ្ទាល់ខ្លួន!" លោកមេ បញ្ជាការបន្ថែមជាចុងក្រោយថា "ព្រះអង្គដឹងទេថាទូលព្រះបង្គំទទួលបញ្ជាផ្ទាល់ពីព្រះបិតាព្រះអង្គ បើព្រះអង្គមានការបន្ទាន់យ៉ាងណានោះ ឬក៏ខ្វះខាតអ្វីត្រូវសុំច្បាប់ តាមទូលបង្គំទូលបង្គំអាចឱ្យគេជូនដំណើរបានដ-ឹងទេ? ដូច្នេះ ព្រះអង្គចេញទៅរៀនវិញចុះ..." ព្រះអង្គ គំនាប់ទទួលបញ្ជា រួចក៏ចេញមកជួបសែពស៊ីម ដែលនៅចាំខាងក្រៅ រួចក៏នាំព្រះអង្គម្ចាស់ដើរសំដៅទៅថ្នាក់រៀនទៅ...ទុកឱ្យលោក កុម៉ង់ដង់ នៅតែមិនដឹង ហើយនៅឆ្ងល់ថា តើព្រះអង្គម្ចាស់ទៅភ្នំពេញធ្វើអី?

(នៅមានត)

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរា ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





**បើថ្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**
- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្ដង់ដា

**ផលប្រយោជន៍ទទួលបាន :**
- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្ដីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

**To be eligibled for GAFC you must:**
- live in subsidized or public housing
- age 22 years and older
- eligible for Masshealth Standard

**Benefits you will get:**
- personal care service in your home,
- Medication Managemant
- an individual care plan developed by a registered nurse and case manager
- ongoing monitoring of needs
- 24-hour access to services

## ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្ដានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852







ក្រុមហ៊ុន ស៊ែល វ៉ាំងន័រ អ៊ីនធ័នាសិនទល (Sherle Wagner International) កំពុងស្វែងរកបុគ្គលិកពេញម៉ោងជួយខាងផ្នែកផលិតទូទៅដែលមានទីតាំងនៅក្រុងហ្វល រីវើ (Fall River) រដ្ឋមាសូឈូសេត។ ការងារមានដូចជាដំណើរការឧបករណ៍ប៉ូលីសឲ្យរលូងដើម្បីធ្វើឲ្យផលិតផល និងចំណែកនៃផលិផលរលូងស្អាតតាមការចង់បាន។ ធ្វើការសំលៀង, ខាត, សំអាត រឺក៏ប៉ូលីសឲ្យរលូងដើម្បីឲ្យស្អាត់បន្ថែមទៀត។ កាន់កន្លែងបញ្ជាម៉ាស៊ីនដើម្បីកែសម្រួលឲ្យដំណើរបានត្រឹមត្រូវ, ចាប់ផ្តើមឲ្យដំណើរការ ឬបញ្ឈប់ម៉ាស៊ីន។ ធ្វើការតម្លើងគ្រឿងមេកានិកតូចៗ ជាមួយឧបករណ៍ប្រើដោយដៃ។

ទំនាក់ទំនងអ៊ីម៉េល jobs@sherlewagner.com

អាស័យដ្ឋាន 1 Lewiston St, Fall River MA

Sherle Wagner International is seeking Full Time General Manufacturing help in our Fall River, MA. location. Operates polishing equipment to obtain desired polish on parts and products. Grind, Sand, Clean or Polish objects for further finishing. Move controls to adjust, start or stop mechanical equipment. General small mechanical assembly with hand tools.

Email: jobs@sherlewagner.com

1 Lewiston St, Fall River MA



# Rhode Island State Police Charges Former Providence Car Dealership Owner and Employees with Allegedly Collecting $150,000 in Illegal Fees

By KhmerPost USA

Providence, RI - Colonel Ann C. Assumpico, Superintendent of the Rhode Island State Police and Director of the Department of Public Safety, announced, on September 25th, that three people have been arrested on charges that they collected $150,610 in illegal fees from 31 customers at the former Douglas Auto Sales car dealership in Providence.

Those arrested were:

Anthony J. Pate, age 73, of 100 Valerie Court, Cranston

Thomas A. Palangio, age 56, of 125 Midway Road, Apt. #108, Cranston

Bruce W. Rogers, age 64, of 500 Warren Ave., East Providence

Mr. Pate is listed as the owner of Douglas Auto Sales. Mr. Palangio, who is listed as the owner of the property, served as its general manager. Mr. Rogers was an employee.

All three were charged with:

Obtaining money under false pretenses ($150,610)

Submitting false documents to an agent, employee or official

Providing false statements to fraudulently obtain license or registration

Forgery

Conspiracy

Obstruction of justice

All three suspects were arrested earlier today and processed at Rhode Island State Police Headquarters. They are scheduled for arraignment in Third Division District Courtlater today.

The arrests stemmed from an investigation initially begun by members of the Rhode Island Division of Motor Vehicles Dealers' License and Regulations Office into the operations and practices of Douglas Auto Sales at 702 Douglas Ave. in Providence. Their findings were presented to the Motor Vehicle Dealers License and Hearing Board, which concluded that Douglas Auto Sales had allegedly violated numerous rules and regulations governing motor vehicle dealerships. The board fined the dealership $518,000 and revoked its license to operate on July 11, 2018. The board also referred the case to the Rhode Island State Police to determine whether there were any criminal violations.

An investigation by members of the Rhode Island State Police Auto Theft and Insurance Fraud Unit found



that the three suspects allegedly presented false statements and documents to obtain a dealers' license.

It further found that Douglas Auto Sales offered a program called "Buy Here, Pay Here," through which consumers with poor credit could purchase vehicles from Douglas Auto Sales, which would provide financing for the vehicle. Consumers would then pay Douglas Auto Sales an agreed-upon amount of money each week until the vehicle was paid off. However, in addition to the agreed-upon sales price for the vehicle, Douglas Auto Sales also allegedly charged customers several fees that they were not entitled to collect, including:

A warranty fee for a warranty that was already included in the cost of the vehicle

An "insurance cap fee" (gap insurance) that they were not allowed to charge because they do not have a license to sell auto insurance

The dealership also allegedly overcharged consumers for a "doc fee" (document preparation fee) covering the cost of preparing documents relating to the sale and registration of the vehicles.

As a result of their investigation, members of the Auto Theft and Insurance Fraud Unit determined that Douglas Auto Sales allegedly charged 31 customers with a total of $150,619 in illegal fees in 2017, alone, and obtained a warrant for all three suspects.

This investigation is continuing. The Rhode Island State Police is searching for other consumers who may have been impacted by the alleged illegal fees.

Anyone who purchased a car within the past three years from Douglas Auto Sales in Providence using the "Buy Here, Pay Here" program is asked to contact Supervisor Kevin Rabbitt or Investigator Anne Mancini at the Division of Motor Vehicles Dealers' License and Regulations Office at (401) 462-5746.

# បុរសបីនាក់ត្រូវបានចាប់ខ្លួនពីបទប្រមូលថ្លៃសេវាខុសច្បាប់ពីការលក់រថយន្ត

លីន-មនុស្ស៣នាក់រស់នៅរដ្ឋរ៉ាត់អាយលិន ត្រូវបានចាប់ខ្លួនដោយចោទប្រកាន់ពីបទបានប្រមូលប្រាក់ខុសច្បាប់ចំនួន១៥០,៦១០ដុល្លារពីអតិថិជនចំនួន៣១នាក់នៅអតីតកន្លែងលក់រថយន្តឈ្មោះ ដូលាស អូតូ សែល (Douglas Auto Sales)ដែលមានទីតាំងនៅក្រុងប្រូវីឌិនកាលពីឆ្នាំ២០១៧ នេះបើតាមការបញ្ជាក់របស់លោកលោកវរសេនីយ៍ឯក កូលូនេល អា ស៊ី អាស្ហូជីខូ ដែលជាប្រធានការិយាល័យប៉ូលីសរដ្ឋរ៉ាត់អាយលិន និងជានាយកនៃនាយកដ្ឋានសុវត្ថិភាពសាធារណៈ បានប្រកាសកាលពីចុងខែវិច្ឆិកា។

បុរសទាំងបីនាក់ដែលចាប់ខ្លួននោះ មានឈ្មោះអាធ័រនី ជេ ផេត អាយុ ៧៣ និង ថូម៉ាស អាផាលិនទូអាយុ៥៦ឆ្នាំ។អ្នកទាំងពីររស់នៅក្រុងក្រាន់ស្តុន។ ចំណែកម្នាក់ទៀតមានឈ្មោះ ប្រូស ដេបមូលយូ រ៉ជឺ អាយុ ៦៤ ឆ្នាំ រស់នៅភាពខាងកើតនៃរដ្ឋរ៉ាត់អាយលិន។ លោក ផេត ត្រូវបានចុះបញ្ជីជាម្ចាស់កន្លែងលក់រយន្តដូលាស់ រីឯលោក ផាលិនទូ ត្រូវបានចុះឈ្មោះជាម្ចាស់ទីតាំង និងមានតួនាទីជាអ្នកគ្រប់គ្រងទូទៅ។ ចំណែកលោក រ៉ជឺ គឺជាបុគ្គលិក។

អ្នកទាំង៣ត្រូវបានចោទប្រកាន់ពីបទទទួលប្រាក់ដោយការបោកបញ្ឆោតចំនួន១៥០,៦១០ ដុល្លារ, ដាក់ឯកសារខ្លែងក្លាយទៅកាន់ទីភ្នាក់ងារ និងមន្ត្រីមានសម្ថកិច្ច និងបុគ្គលិក, ផ្តល់ឯកសារខ្លែងក្លាយដើម្បីទទួលបានអជ្ញាប័ណ្ណរឺការចុះបញ្ជី, ការក្លែងបន្លំ, ការសមគំនិត, និងការរារាំងដល់ប្រព័ន្ធយុត្តិធមិ។ ការចាប់ខ្លួនធ្វើឡើងបន្ទាប់ពីមានការសើបអង្កតដោយការិយាល័យផ្តល់អជ្ញាប័ណ្ណ និងចុះបញ្ជីយានយន្តរបស់ក្រសួងយានយន្តរដ្ឋរ៉ាត់អាយលិនពីដំណើរការអាជីវកម្មរបស់កន្លែងលក់រថយន្ត Douglas Auto Sales ដែលមានទីតាំងនៅផ្លូវ 702 Douglas Ave ក្នុងក្រុងប្រូវីឌិន។

តាមលទ្ធផលនៃការសើបអង្កេតបានរកឃើញថា ទីតាំងអាជីវកម្មខាងលើបានបំពានច្បាប់ និងបទបញ្ញាតិជាច្រើនដែលគ្រប់គ្រងអាជីវកម្មទិញលក់យានយន្ត។ ជាងនេះទៅទៀតគេក៏បានរកឃើញថា ក្រុមហ៊ុនលក់រថយន្ត Douglas បានផ្តល់កម្មវិធីមួយដែលមានឈ្មោះថា "Buy Here, Pay Here" ដោយអតិថិជនដែលមានក្រេឌីតមិនល្អអាចទិញរថយន្តតាមរយៈការផ្តល់ហិរញ្ញប្បទានដោយក្រុមហ៊ុនផ្ទាល់សម្រាប់ទិញរថយន្ត។បន្ទាប់មកអតិថិជនត្រូវបង់ប្រាក់ដល់ក្រុមហ៊ុនទៅតាមចំនួនមួយដែលបានព្រមព្រៀងគ្នា ដោយបង់ប្រាក់មួយសប្តាហ៍ម្តងរហូតដល់រថយន្តនោះត្រូវបានបង់អស់។ តែតំលៃដែលបានព្រមព្រៀងសម្រាប់ទិញរថយន្តនោះ ក្រុមហ៊ុនក៏បានគិតថ្លៃផ្សេងៗជា



ច្រើនទៀតដែលក្រុមហ៊ុនមិនមានសិទ្ធ ដូចជាថ្លៃធានាសម្រាប់ការធានា "រ៉ាបរងដែលត្រូវបានរួមបញ្ចូលរួចហើយនៅក្នុង តម្លៃយានយន្ត, "ការធានា "រ៉ាប់រងលើការបាត់បង់ រឺខូចខាត ដែលក្រុមហ៊ុនមិនត្រូវបានអនុញ្ញាតឱ្យគិតថ្លៃ ដោយសារតែពួកគេមិនមានអាជ្ញាប័ណ្ណក្នុងការលក់ការធានា"រ៉ាប់រងរថយន្តនោះទេ និងការយកកម្រៃរៀបចំឯកសារលើសហួសហេតុទាក់ទងនឹងការលក់ និងចុះបញ្ជីយានយន្ត។

រហូមមកដល់ពេលនេះការសើបអង្កេតនៅតែកំពុងបន្ត។ ប៉ូលីសរដ្ឋរ៉ាត់អាយលិន ក៏កំពុងស្វែងរកអត្ថិថិជនផ្សេងទៀតដែលអាចនឹងត្រូវបានក្រុមហ៊ុនមួយនេះធ្វើការគិតថ្លៃដោយខុសច្បាប់ទៅលើពួកគរ។




# DIVERSITY
## ADULT DAYCARE CENTER

*"A place where your loved ones can call home"*

**What is Adult Day Care:**
We understand that being a fulltime caregiver is a difficult job. When an elderly loved one needs additional care or supervision during the morning or day, it can create stress for the caregivers of the family. Many families think they have no choice but to quit their jobs or to admit their loved ones into a nursing home or assisted living facility. Diversity Adult Daycare Center (DADC) provides a safe supervised community where elderly adults can socialize, enjoy activities and get assistance with personal care. This will allow the caregivers of the family to have peace of mind when they have an appointment, work obligations or simply to enjoy some personal time.

**Benefits of Adult Day Care for Elderly Adults:**
Attending Adult Day Care has many positive benefits for elderly adults. Your loved ones do not have to be at home feeling lonely with no mental stimulation, when the caretakers are occupied. Being in an Adult Day Care creates a feeling of being in a community, where they can have fun and stay healthy with many activities. Your loved ones will look forward to having their independence and meeting their friends. Having friendships that you see every day promotes feelings of self-worth and camaraderie.

**Services we offer at DADC:**
- Nutritious meals and snacks
- Group fitness classes
- Education classes
- Group field trips and outings
- Fun daily entertainment and activities
- Assistance with personal care
- Salon service
- Transportation
- Monthly birthday parties
- Medical staff
- Gardening

**Who is an ideal candidate for Adult Day Care:**
- 55 years and older
- Southeast Asians & Hispanic
  (we are handicap accessible)

**Forms of payment that we accept:**
- We accept private pay
- All major insurances accepted

433 Elmwood Ave. Providence, R.I 02907
P: 401-427-1337 | F: 401-369-7818
www.diversityadc.com | diversityadc@gmail.com

**Se Habla Español**

We speak English, Spanish, Khmer, Lao, Hmong, Portuguese, Russian and Tagalog.
Come and schedule a free tour of our facility. We will provide free assessment and application assistance.
All major insurances and private pay accepted. Medicaid pays for adult day care, there is no cost to you.

# REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY

## WITH COST EFFECTIVE NEWSPAPER ADVERTISING




### DISTRIBUTION

*70+ Locations in Lowell, MA*
*7,000 copies per month*

*25 Locations in Lynn & Revere, MA*
*1,000 copies per month*

*25 Locations in Providence & Cranston, RI*
*2,000 copies per month*

### PUBLISHING

*Two Issues Every Month*

### READERSHIP

*50,000 Monthly*
*600,000 Annually*

### *Khmer Post USA Distribution Locations Include:*

- *Households*
- *Markets*
- *Retail Businesses*
- *Restaurants*
- *Office Buildings*
- *Government Offices*
- *Chamber of Commerce*
- *Buddhist Temples*
- *Laundromats*
- *And Much More*

| 2018 PRINTING DATES | 2018 PRINTING DATES |
|---|---|
| Jan 8 and 22 | July 9 and 23 |
| Feb 5 and 19 | Aug 6 and 20 |
| Mar 5 and 19 | Sept 10 and 24 |
| Apr 9 and 23 | Oct 8 and 22 |
| May 7 and 21 | Nov 5 and 19 |
| Jun 4 and 18 | Dec 3 and 17 |

***Advertising deadlines are 5 business days prior to printing date.***

## ADVERTISING RATES AND SIZES

*All ads are printed in Full Color*

| Ad Size (WxH) | 1 Issue | 3 Months (6 Issues) 5% Savings | 6 Months (12 Issues) 7.5% Savings | 12 Months (24 Issues) 10% Savings |
|---|---|---|---|---|
| **Full** (10” x 13”) | $460 | $2,622 | $5,106 | $9,936 |
| **1/2** (10” x 6.5”) | 310 | 1,674 | 3,441 | 6,696 |
| **1/4** (5” x 6.5”) | 165 | 940 | 1831 | 3,564 |
| **1/8** (5” x 3.25”) | 90 | 513 | 999 | 1,944 |

## CONTACT INFO

**45 Merrimack Street • Suite 218A • Lowell, MA 01852**
**Tel: 978.677.7163 • Fax: 978.677.7092 • Email: sobenpin@khmerpost.us**
**www.khmerpost.us**

*Khmer Post USA is a proud member of the Greater Lowell Chamber and Greater Merrimack Valley Convention and Visitors Bureau*

CELEBRATING 10 YEARS